**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១២២២ សហវ.

ថ្ងៃទី ១៤ ខែ [illegible] ឆ្នាំ ២០០៨

# ប្រកាស

## ស្ដីពី

## ការបង្កើតលេខាធិការដ្ឋាន

## នៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើត ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករាឆ្នាំ ២០០០ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០០៧ ស្ដីពីការកែសំរួលការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញសេចក្ដីសម្រេចលេខ ៥៦ សសរ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០០៧ ស្ដីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- យោងលើភាពចាំបាច់របស់គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង គណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

## សម្រេច

**ប្រការ ១.-**

បង្កើត **«លេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ»** ហៅកាត់ **«លគហស»** ដែលរួមមានសមាសភាពដូចខាងក្រោម ÷

| | |
|---|---|
| ១- លោក **សុខ សារាទុឡ្ឋ** | ប្រធាន |
| ២- លោក **យក់ ម៉ុនណា** | អនុប្រធាន |
| ៣- លោក **ម៉ុន រត្ន័** | មន្ត្រីសម្របសម្រួល |
| ៤- លោក **អ៊ឹម សិទ្ធីរ៉ា** | មន្ត្រីសម្របសម្រួល |
| ៥- លោក **ឆួន ទិត្យ៉ា** | មន្ត្រីសម្របសម្រួល |
| ៦- លោក **ម៉ូ ចន្ទសុខា** | មន្ត្រីសម្របសម្រួល |
| ៧- លោក **សៀង អូនឆួច** | មន្ត្រីសម្របសម្រួល |
| ៨- លោកស្រី **គង់ សុធីរ** | គណនេយ្យករ |
| ៩- លោក **សៀង គង់** | មន្ត្រីលទ្ធកម្ម |

**ប្រការ ២.-**

លេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មាន មុខងារ និង ភារកិច្ចដូចតទៅ÷

- ធ្វើជាលេខាធិការបច្ចេកទេសរបស់គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង គណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងការរៀបចំ និង តាមដានការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។
- គ្រប់គ្រង និង ទទួលខុសត្រូវលើរាល់ការងាររដ្ឋបាល គណនេយ្យ ហិរញ្ញវត្ថុ លទ្ធកម្ម និង រាល់ការងារទំនាក់ទំនងជាមួយក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ ទីប្រឹក្សា ជំនាញការ ក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រោមការដឹកនាំរបស់ប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង គណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។
- ធ្វើជាចំណុចប្រមូលផ្តុំ ក្នុងការផ្តល់ប្រឹក្សា ផ្តល់ការសម្របសម្រួល និង ផ្តល់ការណែនាំផ្សេងៗពាក់ព័ន្ធនឹងការរៀបចំ និង ការតាមដានត្រួតពិនិត្យ ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាមួយគ្រប់ក្រសួង ស្ថាប័ន ពិសេសក្រុមការងារកែទម្រង់ការគ្រប់គ្រង

ហិរញ្ញវត្ថុសាធារណៈជាមួយគ្រប់ក្រសួង ស្ថាប័ន ពិសេសក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំង នាយកដ្ឋាន និង អង្គភាពនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

- ធ្វើជាចំណុចប្រមូលផ្តុំ ក្នុងការបូកសរុបរបាយការណ៍ពីគ្រប់ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅគ្រប់ក្រសួង ស្ថាប័ន និង ពីនាយកដ្ឋាន និង អង្គភាពនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**ប្រការ ៣.-**

ប្រធាន អនុប្រធាន និង មន្ត្រី «លគគហស» បំពេញការងារទៅតាមលក្ខខណ្ឌការងារ និង ទទួលលាភការតាមលទ្ធផលការងារ តាមរយៈការចុះកិច្ចសន្យាការងារដែលសម្រេចដោយប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ «លគគហស» អាចជ្រើសរើសមន្ត្រីជាប់កិច្ចសន្យាដែលមិនមែនជាមន្ត្រីរាជការ អោយមកបំរើការងារ «លគគហស» ដោយមានការឯកភាព ពីប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

**ប្រការ ៤.-**

ប្រធាន អនុប្រធាន និង មន្ត្រី «លគគហស» ព្រមទាំងគ្រប់អង្គភាពពាក់ព័ន្ធ មានភារកិច្ចអនុវត្តប្រកាសនេះឱ្យស្របតាមសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ៥៦ សសរ ស្តីពីការបង្កើត «គគហស» ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០០៧ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០០៨

គាត ឈន់

**ចំលងជូន:**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់ថ្នាក់ដឹកនាំនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- គ្រប់នាយកដ្ឋានក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- សាមីខ្លួន ដើម្បីអនុវត្ត
- កាលប្បវត្តិ ឯកសារ